

# ការរំលោភបំពានផ្លូវភេទកុមារ ជាក់ស្តែងដោយបង្ហាញផ្ទាល់លើអ៊ីនធឺណិត

## និយមន័យ

### ការរំលោភបំពានផ្លូវភេទកុមារជាក់ស្តែងដោយបង្ហាញផ្ទាល់លើអ៊ីនធឺណិត

ការរំលោភបំពានផ្ទាល់តាមវែបខេម (webcam) កើតមានឡើងនៅពេលកុមារត្រូវបានបង្ខំឱ្យបង្ហាញខ្លួននៅមុខវែបខេម (webcam) ដើម្បីចូលរួមការប្រព្រឹត្តិសកម្មភាពផ្លូវភេទ ឬត្រូវគេរំលោភបំពានផ្លូវភេទ។

បន្ទាប់មកសកម្មភាពរំលោភបំពានទាំងនោះ ត្រូវបានគេបង្ហាញផ្ទាល់តាមអ៊ីនធឺណិតទៅកាន់អតិថិជនបង់ប្រាក់ ដែលជា ជនល្មើស - ដែលមើល និង/ឬ ដែលស្នើសុំឲ្យគេបង្ហាញសកម្មភាពរំលោភបំពានជាក់ស្តែងណាមួយតាមវែបខេម (webcam) ។

### ជនល្មើស និងវិធីសាស្ត្ររបស់ពួកគេ

- ជនល្មើស ដែលមើលការរំលោភបំពានកុមារផ្ទាល់តាមវែបខេម (webcam) ជាទូទៅអាចចូលមើលបានដោយ**អន្តរការី ឬអ្នកសម្របសម្រួល**;
- ពេលខ្លះអ្នកសម្របសម្រួលគឺជា**ក្រុមគ្រួសាររបស់**កុមារ ឬ **សមាជិកក្នុងសហគមន៍** ដែលបង្ខំកុមារឲ្យបង្ហាញ ឬសម្តែងនៅមុខវែបខេម (webcam) និងដោយបង្ខំឲ្យទាក់ទងជាមួយ និងទាក់ទាញអតិថិជន (អ្នកដែលអាចនឹងក្លាយជាជនល្មើស);
- ជនល្មើស និងអ្នកសម្របសម្រួល ឬកុមារ**យល់ព្រម**ទៅលើ**ពេលវេលា និងកាលបរិច្ឆេទ** ដែលការរំលោភបំពាននឹងចាប់ផ្តើម និងនៅពេលដែលជនល្មើសនឹងចូលទៅមើល។ ការណាត់ជួបនេះ ត្រូវបានធ្វើឡើងតាមការសន្ទនា សារអេឡិចត្រូនិច ឬទូរស័ព្ទ;
- លើសពីនេះភាគីនានាដែលពាក់ព័ន្ធនឹង**ការយល់ព្រម**ចំពោះ**តម្លៃ**ដែលជនល្មើសនឹងបង់ប្រាក់ ជាទូទៅតាមសេវាកម្មទូទាត់ប្រាក់ស្របច្បាប់ធម្មតា។ ជាទូទៅចំនួនទឹកប្រាក់ដែលបង់នោះ មានចំនួនតិចតួច ដើម្បីបង្ការការសង្ស័យដែលពាក់ព័ន្ធនឹងការផ្ទេរប្រាក់;
- កម្មវិធីផ្សេងៗគ្នា ដូចជា Skype ឬគេហទំព័រទំនាក់ទំនងដែលដំណើរការជាមួយវែបខេម (webcam) ត្រូវបានប្រើប្រាស់ដើម្បី**ផ្សាយ ឬបង្ហាញផ្ទាល់**អំពីការរំលោភបំពានលើអ៊ីនធឺណិត។ ធ្វើដូចនេះគឺអាចឲ្យជនល្មើស **មើលឃើញ**ការរំលោភបំពានជាក់ស្តែង ឬបញ្ជាឲ្យធ្វើសកម្មភាពជាក់លាក់ណាមួយតារយៈ**ដឹកនាំផ្ទាល់**តាមរយៈការសន្ទនា ឬសម្លេង;
- នៅក្នុងសហគមន៍ខ្លះ អាចមាន **ការអត់ឱនក្នុងសង្គមត្រឹមកម្រិតមួយ** ចំពោះបទល្មើសខាងលើ ដែលនេះ ពាក់ព័ន្ធនឹងកត្តាជាច្រើន ដូចជាភាពក្រីក្រ និងការយល់ដឹងនៅមានកម្រិតអំពីអ៊ីនធឺណិត ផលប៉ះពាល់ចំពោះកុមារ ឬភាពមិនស្របច្បាប់ចំពោះអំពើទាំងនោះ។ បន្ទាប់មកការផ្សាយ ឬបង្ហាញផ្ទាល់លើអ៊ីនធឺណិតអំពីសកម្មភាពរំលោភបំពាននឹងក្លាយជាប្រភពចំណូលដែលងាយស្រួលនិងឆាប់រហ័ស។



### គោលការណ៍ច្បាប់

ការរំលោភបំពានផ្ទាល់តាមវែបខេម (webcam) មិនត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌជាក់ច្បាស់នោះទេក្នុងតំបន់ ឬក្នុងគោលការណ៍ច្បាប់អន្តរជាតិស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

ប៉ុន្តែទោះជាយ៉ាងណាក្តីក៏អនុសញ្ញាទីក្រុងឡានហ្សារ៉ូត បានចាត់សកម្មភាពនៃការបង្ក និងបង្ខំកុមារឲ្យពាក់ព័ន្ធនឹងសកម្មភាពអាសអាភាសថាជាបទល្មើព្រហ្មទណ្ឌ តាមតាត្រា (Art. 21(1)(a-b) ក៏ដូចជាការចូលរួមដោយចេតនាក្នុងសកម្មភាពអាសអាភាស (c)។ លើសពីនេះទៀតវាបានចាត់សកម្មភាពនៃការផ្តល់ជំនួយ ឬជួយសម្រួលដល់សកម្មភាពល្មើសទាំងនេះថាជាបទល្មើសព្រហ្មទណ្ឌ តាមតាត្រា (Art. 24) ដែលអាចត្រូវបានប្រើប្រាស់ចំពោះបុគ្គលដែលសម្របសម្រួល ឬការជម្រុញលើកទឹកចិត្តឲ្យមាន ការប្រព្រឹត្តបទល្មើសនេះ។

ពិធីសារដែលជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់ចំណុចការជួញដូរកុមារ (OPSC) មាត្រា 3(1)(a) បានចាត់សកម្មភាពនៃការផ្តល់ ចែកចាយឬទទួលកុមារដោយគ្រប់មធ្យោបាយក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌ។

ដូចគ្នានេះដែរ អនុសញ្ញា ILO 182 មាត្រា 3(b) បានចាត់ការប្រើប្រាស់ ការល្បួងលោម ឬការផ្តល់កុមារឲ្យ [...] សម្រាប់ប្រព្រឹត្តសកម្មភាពផ្លូវភេទ ថាជាបទល្មើសព្រហ្មទណ្ឌ។

មាត្រាទាំងនេះ អាចត្រូវបានបកស្រាយ ដើម្បីដាក់ទោសទណ្ឌលើជនល្មើស ឬអ្នកសម្របសម្រួលសកម្មភាពដែលពាក់ព័ន្ធនឹងការរំលោភបំពានដោយបង្ហាញផ្ទាល់លើអ៊ីនធឺណិត។

ជាទូទៅអនុសញ្ញាប្រចាំតំបន់ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងរូបភាព និងសម្ភារៈអាសអាភាសកុមារមិនអាចត្រូវបានគេយកទៅអនុវត្តចំពោះការរំលោភបំពានដោយបង្ហាញផ្ទាល់លើអ៊ីនធឺណិតនោះទេ គឺព្រោះតែសកម្មភាពរំលោភបំពានទាំងនោះមិនត្រូវបានគេថតចម្លងទុកនោះឡើយ។ ដូចនេះវាមិនត្រូវបានគេ "ផលិត កាន់កាប់ ឬចែកចាយ" ដូចដែលបានចែងក្នុងគោលការណ៍ច្បាប់ក្នុងតំបន់ និងអន្តរជាតិនោះទេ។

## តើលោកអ្នកអាចធ្វើអ្វីខ្លះ?

- លើកកម្ពស់ និងបង្កើនការយល់ដឹងដល់សហគមន៍ឲ្យបានទូលំទូលាយ អំពីភាពមិនស្របច្បាប់ ផលប៉ះពាល់ និងហានិភ័យដែលពាក់ព័ន្ធនឹង ការរំលោភបំពានផ្លូវភេទកុមារដោយបង្ហាញផ្ទាល់លើអ៊ីនធឺណិត។
- តស៊ូមតិដើម្បីឲ្យមានគោលការណ៍ច្បាប់ដែលរឹងមាំ ដែលចាត់រាល់សកម្មភាពអំពីការរំលោភបំពាន ឬភាពអាសអាភាសកុមារថាជាបទល្មើសព្រហ្មទណ្ឌ។
- តស៊ូមតិដើម្បីឲ្យមានធនធានដែលប្រសើរជាងមុន សម្រាប់មន្ត្រីអនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហានេះ
- តស៊ូមិត និងសហការជាមួយអង្គភាពហិរញ្ញវត្ថុឯកជនដើម្បីស៊ើបអង្កេតតាមដានរាល់ចរាចរណ៍សាច់ប្រាក់ដែលគួរឲ្យស្ស័យ ថាអាចពាក់ព័ន្ធនឹងបទល្មើស។

តារាងព័ត៌មានស្តីអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើអ៊ីនធឺណិតនេះផលិតដោយអង្គការ ECPAT អន្តរជាតិ។
ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងផលិតកម្ម ដែលបានផ្តល់ជូនដោយអង្គការ UNICEF។